King County

# ថ្នាំវ៉ាក់សាំងការពារជំងឺខូវីដ១៩ COVID-19

## សេចក្តីសង្ខេប


រដ្ឋបាលគ្រប់គ្រងនិងត្រួតពិនិត្យថ្នាំពេទ្យ (FDA) បានយល់ព្រមអោយអនុម័តប្រើថ្នាំវ៉ាក់ សាំងការពារជំងឺកូវីដ-១៩ ក្នុងលក្ខណ:គ្រាបន្ទាន់សិន។ ក្រសួងសុខភាពសាធារណ: - ទីក្រុង Seattle និង King County កំពុងធ្វើការជាមួយក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីងតោន លើការចែកចាយចាក់វ៉ាក់សាំង។

- ចំនួនវ៉ាក់សាំងវគ្គលើកដំបូងនឹងមានកំណត់ហើយសម្រាប់តែចាក់អោយអ្នកដែល អាចជួបហានិភ័យខ្ពស់បំផុត ដូចជា អ្នកធ្វើការបម្រើផ្នែកសុខភាពនិងអ្នកដែល រស់នៅឯមណ្ឌលថែទាំមនុស្សចាស់ជរាហើយនិងមណ្ឌលថែទាំផ្សេងៗទៀត។
- ថ្នាំវ៉ាក់សាំងការពារជំងឺ COVID-19 នឹងមិនសូវសំបូរទេរហូតដល់ឆ្នាំ 2021 ។ ទីបំផុត ថ្នាំវ៉ាក់សាំងនឹងមានសម្រាប់មនុស្សគ្រប់គ្នាដែលចិតនៅក្នុងក្រុមដែល តម្រូវអោយចាក់វ៉ាក់សាំង។
- សុវត្ថិភាពនៃការចាក់ថ្នាំវ៉ាក់សាំងគឺសំខាន់ជាងគេ។ គ្រប់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ទាំងអស់ត្រូវឆ្លងកាត់ការវិនិច្ឆ័យនិងការសាកល្បងយ៉ាងម៉ឹងម៉ាត់ជាច្រើនដំណាក់កាល ហើយនិងឆ្លងកាត់ទម្រង់ការអនុម័តជាច្រើនទៀតមុនគេអាចយកវាមកប្រើការបាន។ គេនឹងយល់ព្រមអោយអនុម័ត ប្រសិនបើវាឆ្លងផុតស្តង់ដារសុវត្ថិភាពនិងប្រសិទ្ធភាព របស់ FDA តែប៉ុណ្ណោះ។ វ៉ាក់សាំងនឹងត្រូវបានត្រួតពិនិត្យមើលសុវត្ថិភាពផងដែរ នៅពេលគេយកវាមកចាក់អោយអ្នកជំងឺ។


## ការផ្គត់ផ្គង់ចំនួនវ៉ាក់សាំង COVID-19 ពីដើមដំបូងនឹងមានកំណត់ហើយចាំបាច់ សម្រាប់តែអ្នកមានអាទិភាពមុនគេ +

នៅទីបំផុត មនុស្សគ្រប់ៗគ្នាដែលចង់ចាក់វ៉ាក់សាំងនឹងអាចចាក់បាន។ ទោះយ៉ាងណាក៏ដោយ នៅពេលវ៉ាក់សាំងចេញ មកជាដំបូង ចំនួនផ្គត់ផ្គង់នឹងមានកំណត់។ វ៉ាក់សាំង ជាដំបូងនឹងត្រូវចាក់អោយប្រជាជនណាដែលមានហានិភ័យ ខ្ពស់បំផុតក្នុងការកើតជំងឺ ខូវីដ១៩ ឬអាចមានបញ្ហាសុខភាពធ្ងន់ធ្ងរ ប្រសិនបើពួកគេឆ្លងជំងឺខូវីដ១៩ ដូចជាបុគ្គ លិកបម្រើការងារផ្នែកសុខភាពមនុស្សវ័យចំណាស់ដែលកំពុងរស់នៅក្នុងមណ្ឌល ថែទាំឬជួយឧបត្ថម្ភក្នុងការរស់នៅ ហើយនិងបុគ្គលិកការងារចាំបាច់ផ្សេងៗទៀត។

## ឥឡូវនេះអ្នកណាអាចចាក់វ៉ាក់សាំងបាន +

ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីងតោន (DOH) គឺជាអ្នកសម្រេចលើការចែកចាយវ៉ាក់សាំងសម្រាប់រដ្ឋរបស់យើង។ បច្ចុប្បន្ននេះ យើងកំពុងស្ថិតក្នុងដំណាក់កាលចែកចាយដំបូងគេបង្អស់ហៅថា ដំណាក់កាលទី 1a “Phase 1a” ។ ក្នុងដំណាក់កាលទី1a បុគ្គលិកធ្វើការនៅក្នុងមណ្ឌលថែទាំសុខភាពដែលមានហានិភ័យខ្ពស់និងអ្នករស់នៅតាមមណ្ឌលថែទាំ (ដូចជាមណ្ឌលថែទាំមនុស្សចាស់ជរាមណ្ឌលផ្តល់ជំនួយដល់ការរស់នៅនិងកន្លែងថែទាំមនុស្សពេញវ័យ) អាចចាក់វ៉ាក់ សាំងបាន។

ក្រសួង DOH បានផ្តល់វ៉ាក់សាំងទៅមន្ទីរពេទ្យ ឱសថស្ថានហើយនិងប្រព័ន្ធថែទាំសុខភាពជាច្រើនដែលបានចុះឈ្មោះ ដើម្បីទទួលថ្នាំវ៉ាក់សាំង។ ក្រសួង DOH និងក្រសួងសុខភាពសាធារណ: - Seattle និង King County កំពុងធ្វើការជាមួយដៃគូជាច្រើនដើម្បីបង្កើនចំនួនកន្លែងចាក់វ៉ាក់សាំងនិងបង្កើនអោយមានថ្នាំវ៉ាក់សាំងកាន់តែច្រើន។

អ្នករស់នៅតាមមណ្ឌលថែទាំនិងបុគ្គលិកធ្វើការនៅទីនោះជាច្រើននាក់នឹងបានទទួលការចាក់វ៉ាក់សាំងពីឱសថស្ថានដែល ជាដៃគូរបស់ពួកគេ។

ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីងតោន DOH កំពុងធ្វើការសាកល្បងដោយប្រើឧបករណ៍ក្នុងដំណាក់កាលស្វែងរកអ្នកមានលក្ខណ:សម្បត្តិចាក់វ៉ាក់សាំង http://www.findyourphasewa.com/ គឺជាដំណាក់កាលធ្វើវិនិច្ឆ័យដោយខ្លួន ឯងតាមអនឡាញដើម្បីជួយ រកមនុស្សមានលក្ខណ: សម្បត្តិចាក់វ៉ាក់សាំងក្រោមដំណាក់កាលទី 1a។ ដំណាក់កាលស្វែងរកក៏នឹងផ្តល់ជូនដូចខាងក្រោមផងដែរ៖

- ការបញ្ជាក់នៃលក្ខណ:សម្បត្តិដែលអាចបង្ហាញអោយឃើញនៅទីតាំងចាក់វ៉ាក់សាំង
- ការតភ្ជាប់ទៅគេហទំព័របញ្ជីឈ្មោះទីតាំងចាក់វ៉ាក់សាំង

ដំណាក់កាលស្វែងរក បច្ចុប្បន្ននេះ ស្វែងរកតែអ្នកណាដែលមានលក្ខណ:សម្បត្តិសម្រាប់ដំណាក់កាលទី 1a ប៉ុណ្ណោះ ប៉ុន្តែគេនឹងបើកសម្រាប់ក្រុមអាទិភាពផ្សេងទៀតនៅពេលដែលរដ្ឋឈានទៅកាន់ដំណាក់កាលថ្មីចែកចាយថ្នាំវ៉ាក់សាំង។

## ការចំណាយលើការចាក់វ៉ាក់សាំង +

- Medicare, Medicaid ហើយនិងការធានារ៉ាប់រងសុខភាពភាគច្រើននឹងចេញ ថ្លៃចាក់វ៉ាក់សាំងការពារជំងឺខូវីដ ហើយគេនឹងចេញថ្លៃចាក់វ៉ាក់សាំងអោយអ្នកដែល គ្មានធានារ៉ាប់រងសុខភាព។ លោកអ្នកប្រហែលជាបង់ថ្លៃឈ្នួលខ្លះឬថ្លៃឈ្នួលទៅជួបពេទ្យអាស្រ័យទៅលើផែនការធានារ៉ាប់រងសុខភាពរបស់អ្នកឬគ្រូពេទ្យដែលអ្នកទៅ ជួបដើម្បីចាក់វ៉ាក់សាំង។
- ក្រសួងសុខភាពសាធារណ:ក៏កំពុងរៀបចំផែនការបើកមន្ទីរចាក់វ៉ាក់សាំងដោយឥតគិតថ្លៃនៅពេលមានចំនួនវ៉ាក់សាំងគ្រប់គ្រាន់។

## សុវត្ថិភាពនៃថ្នាំវ៉ាក់សាំងសំខាន់ជាងគេ +

ថ្នាំវ៉ាក់សាំងការពារជំងឺខូវីដ១៩ COVID-19 ត្រូវឆ្លងកាត់ការសាកល្បងព្យា បាលយ៉ាងហ្មត់ចត់ដែលមានអ្នកចូលរួមសាកល្បងរាប់ពាន់នាក់ បានចាក់វ៉ាក់សាំងនេះ។ ការអនុម័តសម្រាប់ការប្រើប្រាស់ត្រូវអនុវត្តតាមជំហានទាំងនេះ។ រដ្ឋបាលត្រួតពិនិត្យ ថ្នាំពេទ្យ (FDA) វិភាគទិន្នន័យ វិទ្យាសាស្រ្តពីការសាកល្បងទាំងនេះដើម្បីកំណត់ពី សុវត្ថិភាពនិងប្រសិទ្ធភាពនៃវ៉ាក់សាំងនីមួយៗ។ រដ្ឋបាល FDA រំពឹងលើការវិភាគនិង អនុសាសពីក្រុមប្រឹក្សាអ្នកវិទ្យាសាស្រ្តនិងអ្នកជំនាញឯករាជ្យ ដែលគេហៅថា គណកម្មការក្រុមប្រឹក្សាទាក់ទងនិងផលិតផលជីវសាស្រ្តនិងវ៉ាក់សាំង Vaccines and Related Biological Products Advisory Committee (VRBPAC)។ អង្គប្រជុំរបស់ VRBPAC បើកអោយសាធារណ:ចូលរួម។

ប្រសិនបើវ៉ាក់សាំងត្រូវនឹងខ្នាតស្តង់ដារសុវត្ថិភាពនិងប្រសិទ្ធភាពរបស់រដ្ឋបាល FDA, FDA អាចបើកអោយប្រើវ៉ាក់សាំងនេះ នៅសហរដ្ឋ អាមេរិក តាមរយ:អាជ្ញាប័ណ្ណបែប បុរាណឬអនុញ្ញាតអោយប្រើក្នុងលក្ខណ:គ្រាបន្ទាន់សិន។

ក្រោយពីរដ្ឋបាល FDA បានធ្វើការសម្រេចចិត្តរបស់ខ្លួនហើយ ស្ថាប័នប្រឹក្សាឯក រាជ្យនៃអ្នកជំនាញផ្នែកពិនិត្យថ្នាំវ៉ាក់សាំងទី២និងគណ:កម្មាធិការប្រឹក្សាអនុវត្តថ្នាំ វ៉ាក់សាំងនៃសហរដ្ឋអាមេរិក the US Advisory Committee on Im-munizationPractices (ACIP) នឹងត្រួតពិនិត្យទិន្នន័យសុវត្ថិភាពនិងប្រសិទ្ធ ភាពនៃថ្នាំវ៉ាក់សាំងហើយផ្តល់អនុសាសន៍ ទៅក្រសួងគ្រប់គ្រងជំងឺ CDC ពីគោល ការណែនាំសម្រាប់អ្នកថែទាំសុខភាពនិងសាធារណ:អំពីការប្រើវ៉ាក់សាំងនេះ។

## ការត្រួតពិនិត្យសុវត្ថិភាពថ្នាំវ៉ាក់សាំង

ក្រោយពីថ្នាំវ៉ាក់សាំងត្រូវបានអនុញ្ញាតអោយយកមកប្រើប្រាស់ហើយ គេក៏ដាក់ ប្រព័ន្ធ ត្រួតពិនិត្យសុវត្ថិភាព ជាច្រើន Safety monitoring systems ដើម្បីតាម ដានផលប៉ះពាល់ដែលអាចកើតឡើង។ ប្រសិនបើផលប៉ះពាល់ធ្ងន់ធ្ងរត្រូវបានរកឃើញ ដែលគេមិនបានរំពឹងទុកជាមុន អ្នកជំនាញនឹងធ្វើការឱ្យបានយ៉ាងឆាប់រហ័សដើម្បី កំណត់ថា តើវាពិតជាគួរអោយព្រួយបារម្ភណ៍

ពីសុវត្ថភាព មែនឬអត់។ នេះគឺជាដំណើរ ការបន្តវិភាគសុវត្ថិភាពទោះបីជាការសាកល្បងព្យាបាលត្រូវបានបញ្ចប់ក៏ដោយ។ ចំពោះ ថ្នាំវ៉ាក់សាំងការពារជំងឺខូវីដ១៩ COVID-19 ក្រសួង CDC និង រដ្ឋបាល FDA បានពង្រីកប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាព ដើម្បីវិភាគមើលសុវត្ថិភាពដោយ យកចិត្តទុកដាក់និងធានាថា ថ្នាំវ៉ាក់សាំងចាក់ការពារជំងឺខូវីដ១៩មានសុវត្ថិភាព ដ៏ល្អជាទីបំផុត។

- ចំពោះព័ត៌មានបន្ថែមស: ដើម្បីធានាសុវត្ថិភាពនៃថ្នាំវ៉ាក់សាំងការពារជំងឺខូវីដ១៩នៅសហរដ្ឋអាមេរិក CDC

## មានតែអ្នកជំនាញខាងសុខភាពដែលមានបំណ្ណអនុញ្ញាតនិងការហ្វឹកហ្វឺនទេទើបអាចចាក់ថ្នាំវ៉ាក់សាំងអោយអ្នកជំងឺបាន។

មានតែបុគ្គលដែលមានបំណ្ណអនុញ្ញាតនិងការហាត់ហ្វឹកហ្វឺនប៉ុណ្ណោះទើបអាចចាក់ថ្នាំ វ៉ាក់សាំងអោយអ្នកជំងឺបាន។ នៅពេលថ្នាំវ៉ាក់សាំងមានកាន់តែច្រើនសម្រាប់សាធារណៈ ជនទូទៅ អ្នកផ្តល់សេវាថែទាំសុខភាពជាច្រើនប្រភេទនឹងផ្តល់ថ្នាំវ៉ាក់សាំងតាម លំដាប់លំដោយ។ អ្នកផ្តល់សេវាទាំងនេះអាចផ្តល់ការចាក់ថ្នាំវ៉ាក់សាំងទាំងនៅ ក្នុងមន្ទីរសុខភាពនិងមន្ទីរពេទ្យហើយនិងនៅតាមព្រឹត្តិការណ៍ចល័តឬព្រឹត្តការណ៍ ជាច្រើនផ្សេងៗទៀតនៅក្នុងសហគមន៍។

## ចំណុចសំខាន់ៗដើម្បីបន្តរសុវត្ថិភាពការពារជំងឺកូវីដ១៩ COVID-19 +

- វ៉ាក់សាំងដែលមានសុវត្ថភាពនិងប្រសិទ្ធិភាពអាចទប់ស្កាត់ជំងឺកូវីដ១៩បាន គឺជាការរកឃើញដ៏ធំធេងមួយ។ ប៉ុន្តែវ៉ាក់សាំងតែមួយមុខគត់គឺមិនអាចបញ្ឈប់ជំងឺរាតត្បាតនេះ បានទេ។
- ទោះបីជាក្រោយពីមានវ៉ាក់សាំងចាក់ការពារដ៏ដោយ ការបញ្ឈប់ជំងឺរាតត្បាតនឹងតម្រូវ អោយយើងគ្រប់ៗគ្នា បន្តគោរព តាមគោលការណែនាំដើម្បីការពារខ្លួននិងអ្នកដ៏ទៃ ទោះបីជាពួកគេបានចាក់វ៉ាក់សាំងការពារហើយក៏ដោយ។ នេះមានរួម បញ្ចូលទាំង ការពាក់ម៉ាស់ នៅអោយឆ្ងាយពីគ្នាចំងាយ៦ហ្វីត ដាក់កំណត់លើសកម្មភាពទាំង ឡាយនៅខាងក្រៅ ផ្ទះហើយនិងជៀសវាងទីប្រជុំជន លាងដៃអោយបានញឹកញាប់ គោរពតាមការណែនាំរបស់ក្រសួងគ្រប់គ្រងជំងឺ CDC អំពីការធ្វើដំណើរ ហើយនិង គោរពតាមការណែនាំឃុំខ្លួនក្រោយពីបាននៅជិតនរណាម្នាក់កើតជំងឺកូវីដ១៩។

## សំណួរដែលត្រូវបានគេសួរជាញឹកញាប់អំពីថ្នាំវ៉ាក់សាំងការពារជំងឺកូវីដ

## ចំពោះព័ត៌មានបន្ថែមអំពីថ្នាំវ៉ាក់សាំងការពារជំងឺខូវីដ១៩ (COVID-19)

- ហទំព័ររបស់ក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីងតោនអំពី វ៉ាក់សាំងជំងឺខូវីដ១៩ COVID-19 Vaccine webpage
- គេហទំព័ររបស់ក្រសួង CDC អំពី វ៉ាក់សាំងជំងឺខូវីដ១៩ CDC COVID-19 Vaccines website
- ៨ចំណុចពីក្រសួងCDC ដែលអ្នកត្រូវដឹងអំពីផែនការចាក់វ៉ាក់សាំង

☐ **Link/share our site at www.kingcounty.gov/covid/vaccine/khmer**

Last Updated January 14, 2021